# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សម រង្ស៊ី
ផ្ទះលេខ ៣៨ ផ្លូវលេខ ៣០៦
សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន
ភ្នំពេញ

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ១៩៩៥

## ខ្ញុំបាទ សម រង្ស៊ី តំណាងរាស្ត្រមណ្ឌល ខេត្តសៀមរាប

## សូមគោរពជូន

## សម្តេច ជា ស៊ីម ប្រធានសភាជាតិ

សម្តេចប្រធាន ជាទីគោរព,

ដូចខ្ញុំបានជំរាប សម្តេចរួចមកហើយ ក្នុងលិខិតរបស់ខ្ញុំផ្ញើជូនសម្តេច ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៥ ខ្ញុំមិនទទួលស្គាល់ឡើយ នូវសេចក្តីសំរេចរបស់គណៈកម្មាធិការនាយក នៃគណបក្សហ្វ៊ុនស៊ិនប៉ិច ធ្វើនៅថ្ងៃទី ១៣ ឧសភា ១៩៩៥ ដែលអះអាងថា បានបញ្ចប់សមាជិកភាពរបស់ខ្ញុំ ពីគណបក្សរួចមកហើយ ។ នៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៩៥ ខ្ញុំបានដាក់ពាក្យបណ្តឹងទៅតុលាការរាជធានីភ្នំពេញ សុំឱ្យតុលាការលុបចោល នូវសេចក្តីសំរេចខុសច្បាប់នេះ ។ តែនៅថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ១៩៩៥ លោកប្រធានតុលាការរាជធានីភ្នំពេញ បានសរសេរលិខិតមកខ្ញុំមួយច្បាប់ អះអាងថា រឿងក្តីរបស់ខ្ញុំនេះ " ពុំស្ថិតក្នុងសមត្ថកិច្ចរបស់តុលាការក្រុងភ្នំពេញទេ ។ គឺជាវិវាទរបស់សមាជិកបក្ស ជាមួយអង្គការបក្សមួយ ដែលអាស្រ័យដោយគណបក្សនោះជាអ្នកដោះស្រាយ " ។ នៅថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ១៩៩៥ នេះ ខ្ញុំទើបតែបានសរសេរលិខិតមួយទៀត ជូនលោកប្រធានតុលាការរាជធានីភ្នំពេញដែល សុំឱ្យលោកពិនិត្យឡើងវិញ លើសេចក្តីអះអាងរបស់លោក ស្តីពីសមត្ថកិច្ចរបស់តុលាការ ។

តាមគោលការណ៍ច្បាប់ និង នីតិវិធីតុលាការ ដែលគេអនុវត្តនៅគ្រប់ប្រទេស ដែលប្រកាន់លទ្ធិប្រជាធិបតេយ្យ ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិតវ៉ា ចំពោះសេចក្តីសំរេចទាំងឡាយរបស់តុលាការដំបូង ហើយអាចបញ្ជូនសំណុំរឿងរបស់ខ្លួន ដើម្បីសុំការវិនិច្ឆ័យ ពីសាលាឧទ្ធរណ៍ ។ ដូច្នេះ រឿងក្តីរបស់ខ្ញុំ ជាមួយនឹងថ្នាក់ដឹកនាំគណបក្សហ្វ៊ុនស៊ិនប៉ិច ស្ថិតនៅក្រោមការគ្រប់គ្រងរបស់តុលាការនៅឡើយ ហើយតុលាការច្បាស់ជានឹងមិនរំលោភរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលបានចែងជាអាទិ ក្នុងមាត្រា ១០៩ ថា: " អំណាចតុលាការ ជាអំណាចឯករាជ្យ " ហើយ " អំណាចតុលាការគ្របដណ្តប់លើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង " ។ ដូច្នេះ ក្នុងពេលដែលខ្ញុំកំពុងតែធ្វើតាមនីតិវិធីតុលាការ ដើម្បីឱ្យតុលាការផ្តល់យុត្តិធម៌ឱ្យខ្ញុំ ខ្ញុំសូមសម្តេចប្រធានមេត្តាធានា ការគោរព ការបែងចែកអំណាចឱ្យដាច់ពីគ្នារវាង អំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និង អំណាចតុលាការ ដូចមានចែងក្នុងមាត្រា៥១ នៃរដ្ឋធម្មនុញ្ញ ។

ដូច្នេះដរាបណា តុលាការរាជធានីភ្នំពេញ មិនទាន់បានបញ្ជាក់សារជាថ្មី នូវគោលជំហររបស់លោក លើពាក្យបណ្តឹងរបស់ខ្ញុំ បន្ទាប់ពីលោកបានទទួលលិខិតរបស់ខ្ញុំ ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ១៩៩៥ នេះ ហើយដរាបណាសាលាឧទ្ធរណ៍ ក៏មិនទាន់មានឱកាស បញ្ជាក់នូវគោលជំហររបស់លោក លើរឿងក្តីខ្ញុំនេះដែរ ដរាបនោះគ្មានបុគ្គលណា ឬ អង្គការណាអាចអះអាងថា ខ្ញុំបានត្រូវ

គេបញ្ឈប់សមាជិកភាពរបស់ខ្ញុំ ពីគណបក្សហ្វ៊ុនស៊ិនប៊ិច ជាស្ថាពរបានឡើយ ។ ដូច្នេះរដ្ឋសភាមិនត្រូវសំអាងលើ បន្ទូលអះអាងរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ថា ខ្ញុំឈប់ជាសមាជិកហ្វ៊ុនស៊ិនប៊ិចហើយ ដើម្បីលើកបញ្ហាអាសនៈរបស់ខ្ញុំ នៅរដ្ឋសភាមកពិភាក្សា ។

សូមរដ្ឋសភា កុំលូកដៃក្នុងរឿងផ្ទៃក្នុងគណបក្សហ្វ៊ុនស៊ិនប៊ិច ហើយកុំលូកដៃក្នុងកិច្ចការរបស់តុលាការ ដោយសារថា មិនទាន់មានសេចក្តីសំរេចអ្វីជាស្ថាពរ ដែលមិនអាចប្រកែកតវ៉ាបាន ពីសំណាក់តុលាការនៅឡើយទេ ។ យ៉ាងហោចណាស់ ក៏នៅមានសាលាឧទ្ធរណ៍ និង តុលាការកំពូលទៀតដែរ ។ ខ្ញុំបានបង្ហាញនូវភ័ស្តុតាង និង ឯកសារថ្មីៗជាច្រើនដែលបញ្ជាក់ឱ្យឃើញថា សេចក្តីសំរេចរបស់គណៈកម្មាធិការនាយកគណបក្សហ្វ៊ុនស៊ិនប៊ិច ពាក់ព័ន្ធនឹងរូបខ្ញុំ គឺមានលក្ខណៈខុសច្បាប់ពេញទី ដោយមានការរំលោភជាក់ស្តែង គ្រប់បែប គ្រប់យ៉ាង លើលក្ខន្តិកៈ និង បទបញ្ជាផ្ទៃក្នុង របស់គណបក្ស ។

ទន្ទឹមនឹងនេះ ខ្ញុំក៏បានសរសេរលិខិតមួយ ទៅថ្វាយព្រះមហាក្សត្រ ដើម្បីទូលសុំព្រះរាជតំរិះដ៏ខ្ពង់ខ្ពស់ពីព្រះអង្គ ដោយសារថា ព្រះអង្គ " ទ្រង់ជាអ្នកធានាឯករាជ្យ នៃអំណាចតុលាការ " ( មាត្រា ១១៣ នៃរដ្ឋធម្មនុញ្ញ ) ហើយដោយសារថា " ឧត្តមក្រុមប្រឹក្សានៃអង្គ ចៅក្រមស្ថិតក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ " ( មាត្រា ១១៥ នៃរដ្ឋធម្មនុញ្ញ ) ។ ដូច្នេះ យើងទាំងអស់គ្នាគួររង់ចាំ ព្រះរាជតំរិះដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្រសិន ទាក់ទងនឹងសមត្ថកិច្ចរបស់តុលាការនេះ មុននឹងយកបញ្ហារបស់សមាជិករដ្ឋសភាណាម្នាក់ មកពិភាក្សា ។

សូមសម្តេចប្រធាន មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំ ។

Sam Rainsy

សម រង្ស៊ី

<u>ឯកសារភ្ជាប់:</u>

- លិខិតចុះថ្ងៃទី០២ មិថុនា ១៩៩៥ ផ្ញើជូនប្រធានតុលាការ
  រាជធានីភ្នំពេញ
- សេចក្តីថ្លែងការណ៍ ចុះថ្ងៃទី ៣១ ឧសភា ១៩៩៥
  របស់សមាជិកគណបក្សហ្វ៊ុនស៊ិនប៊ិចមួយក្រុម
- យោបល់អ្នកច្បាប់ទាក់ទងនឹងរឿងក្តី ហ្វ៊ុនស៊ិនប៊ិច_សម រង្ស៊ី